**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខៈ ៣៤៣ ប.ក សក

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យយានយន្ត ធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន



មហាវិថីព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារៈ (៨៥៥) ២៣ ៤២៧ ៨៦២

# សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងយានជំនិះដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក និងការដឹកជញ្ជូនទំនិញនិងអ្នកដំណើរតាមយានជំនិះ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅដូចខាងក្រោម៖

- កំណត់លក្ខខណ្ឌ និងនីតិវិធីនៃការអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
- កំណត់បរិមាណទំនិញគិតជា តោន/គ.ម ឬអ្នកដំណើរគិតជា នាក់/គ.ម។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះយានជំនិះ ដែលប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និងដឹកជញ្ជូនអ្នកដំណើរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ត្រូវបានលើកលែងចំពោះរថយន្តជាកម្មសិទ្ធិរដ្ឋដែលបម្រើសេវាដឹកជញ្ជូនសាធារណៈ។

**ប្រការ៤.-**

យានយន្ត រ៉ឺម៉ក ដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ត្រូវមានលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ហើយត្រូវដាក់តាមយានយន្តជាប្រចាំ នៅគ្រប់ពេលធ្វើចរាចរណ៍នៅតាមផ្លូវថ្នល់។

នីតិបុគ្គល រូបវន្តបុគ្គល ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស តាមគំនូសបំព្រួញដូចមានចែងក្នុង**ឧបសម្ព័ន្ធទី១**និងនីតិវិធីខាងក្រោម៖

- ត្រូវដាក់ពាក្យស្នើសុំតាមប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកដែលមានអាសយដ្ឋាន transportlicense.mpwt.gov.kh និងបង់ប្រាក់កម្រៃសេវាសាធារណៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទៅដៃគូណាមួយដែលធ្វើប្រតិបត្តិការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន
- ពាក្យស្នើសុំនឹងត្រូវបានអនុម័ត ក្រោយពេលបង់ប្រាក់រួច និងពិនិត្យឃើញថាត្រឹមត្រូវតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ក្រោយការអនុម័តលើពាក្យស្នើសុំ អ្នកដាក់ពាក្យនឹងត្រូវបានជូនដំណឹង ឲ្យយកសំណុំឯកសារដើម ភ្ជាប់ជាមួយនឹងពាក្យស្នើសុំ និងវិក្កយបត្របង់ប្រាក់ ទៅទីតាំងផ្ដល់សេវាដែលកំណត់ដោយក្រសួង ដើម្បីផ្ទៀងផ្ទាត់ថាពិតជាត្រឹមត្រូវដើម្បីប្ដូរយកលិខិតអនុញ្ញាត។

ទម្រង់ឯកសារភ្ជាប់នឹងពាក្យស្នើសុំរួមមាន៖

- បណ្ណសម្គាល់យានយន្ត
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះដែលមានសុពលភាព
- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសចំពោះក្រុមហ៊ុន។

**ប្រការ៥.-**

យានយន្តជាសមាជិករបស់ភ្នាក់ងារផ្ដល់សេវាដឹកជញ្ជូនដោយចែករំលែកយានជំនិះ មិនតម្រូវឲ្យមានលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មទេ។